UNDP Cambodia

# របាយការណ៍ប្រចាំឆ្នាំ ២០០៩



លើកកំពស់យោបល់ ជម្រើស និងអនាគតប្រកបដោយនិរន្តរភាព

# បុព្វកថា

ក្នុងនាមជានាយកការិយាល័យយូអិនឌីភីប្រចាំប្រទេសកម្ពុជាដែលបានបញ្ចប់អាណត្តិទៅហើយ ខ្ញុំមានសេចក្តីរីករាយបង្ហាញជូនរបាយការណ៍ប្រចាំឆ្នាំ ២០០៩ របស់យើង និងសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះ លោកស្រី អេលេណា ទីឆេនកូ ដែលបានចូលកាន់តំណែងជានាយកថ្មី។ ខ្ញុំមានកិត្តិយសណាស់ដែលបានបម្រើការនៅក្នុងការិយាល័យនេះ ហើយខ្ញុំក៏មានមោទនភាពពន់ពេកដែរក្នុងការផ្ទេរទៅឱ្យលោកស្រី ទីឆេនកូ នូវកម្មវិធីមួយដែលខ្ញុំជឿថាមានការផ្តោតចំគោលដៅបានល្អ និងសម្លឹងទៅអនាគតខាងមុខ។

របាយការណ៍នេះបង្ហាញពីសមិទ្ធផលចំបង១សម្រាប់ឆ្នាំ ២០០៩ ប៉ុន្តែក៏ពិនិត្យមើលផងដែរនូវការលំបាកនានាដែលយើងបានប្រឈម ដូចជាវិបត្តិសេដ្ឋកិច្ចពិភពលោក ដែលមានឥទ្ធិពលយ៉ាងខ្លាំងមកលើកម្ពុជាកាលពីឆ្នាំទៅ។

នៅឆ្នាំ ២០០៩ យូអិនឌីភី បានរួមវិភាគទានយ៉ាងច្រើន ទៅក្នុងការអភិវឌ្ឍរបស់ប្រទេសនៅក្នុងផ្នែកគន្លឹះចំនួនបួនគឺ ១ - ការគាំទ្រដល់កំណែទម្រង់វិមជ្ឈការនៅមូលដ្ឋាន ២ - ការសម្រួលឱ្យមានការពិភាក្សាលើគោលនយោបាយអំពីអភិបាលកិច្ចខាងសេដ្ឋកិច្ច និងការបញ្ជ្រាបយេនឌ័រ ៣ - ការពង្រឹងយន្តការប្រសិទ្ធភាពជំនួយ និង ៤ - ការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងការបង្ហាញពីការឆ្លើយតបរបស់ខ្លួន ចំពោះការប្រែប្រួលអាកាសធាតុ។ កិច្ចការទាំងនេះនឹងមិនអាចកើតឡើងបានឡើយ ប្រសិនបើគ្មានភាពជាដៃគូយុទ្ធសាស្ត្ររបស់យើងជាមួយ SIDA, DFID, EU, AusAID, CIDA និងស្ថាប័នដទៃទៀតជាច្រើន។

នៅក្នុងផ្នែកអភិបាលកិច្ចមូលដ្ឋាន ទឹកប្រាក់សរុបចំនួន ៨២ លានដុល្លា ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា និងម្ចាស់ជំនួយនានាផ្តល់ឱ្យតាមរយៈរចនាសម្ព័ន្ធ និងប្រព័ន្ធរបស់រដ្ឋាភិបាល ដែលគាំទ្រដោយយូអិនឌីភី ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធ កែលំអសេវាកម្មសុខភាព និង សិទ្ធិទទួលបានការអប់រំ និងបង្កើនការយល់ដឹងអំពីសិទ្ធិរបស់ស្ត្រី និងកុមារ។ បន្ទាប់ពីមានការបោះឆ្នោតជាលើកដំបូងដើម្បីជ្រើសរើសក្រុមប្រឹក្សាខេត្ត និងស្រុកដែលធ្វើឡើងនៅក្នុងខែ ឧសភា ក្រុមប្រឹក្សាដែលបានជាប់ឆ្នោតថ្មី១នៅថ្នាក់ស្រុកក៏ដូចជាបុគ្គលិកនៅថ្នាក់ខេត្ត និងស្រុក បានទទួលការបណ្តុះបណ្តាល ដើម្បីជួយពួកគេក្នុងការអនុវត្តមុខនាទីថ្មីរបស់ខ្លួន។ វេទិកាថ្នាក់ខេត្ត និងស្រុក ដែលចាត់ចែងឡើង ដោយសម្ព័ន្ធភាពជាតិឃុំ/សង្កាត់បានអនុញ្ញាតឱ្យក្រុមប្រឹក្សាឃុំ ពង្រឹងទំនាក់ទំនងរបស់ពួកគេជាមួយក្រសួងពាក់ព័ន្ធ និងសភាជាតិ។

តាមរយៈភាពជាដៃគូជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ យូអិនឌីភីបានជួយកសាងគោលនយោបាយជាតិស្តីពីភាពប្រកួតប្រជែងខាងសេដ្ឋកិច្ច និងផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច។ ដោយធ្វើការជាមួយក្រសួងកិច្ចការនារី យើងបានជួយបញ្ជ្រាបកិច្ចការយេនឌ័រទៅក្នុងគោលនយោបាយជាតិ និងគោលនយោបាយតាមវិស័យ។ ជាលទ្ធផល កិច្ចការខាងយេនឌ័រ ត្រូវបានបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម និងកម្មវិធីជាតិសម្រាប់រយៈពេល ១០ ឆ្នាំ ស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ យុទ្ធសាស្ត្រសមធម៌យេនឌ័រ សម្រាប់រយៈពេល ៥ ឆ្នាំ ក៏ត្រូវបានរៀបរៀងឡើងដោយក្រសួងកិច្ចការនារីផងដែរ។

ដើម្បីកែលម្អប្រសិទ្ធភាពជំនួយ និងលើកកំពស់ស្មារតីនៃភាពជាម្ចាស់របស់ជាតិ យូអិនឌីភីបានគាំទ្រដល់រដ្ឋាភិបាលក្នុងការអនុវត្តអភិក្រមដែលផ្អែកលើកម្មវិធីសម្រាប់ការបញ្ជ្រាបកិច្ចការយេនឌ័រ រៀបរៀងសេចក្តីព្រាងគោលការណ៍ភាពជាដៃគូសម្រាប់ការប្រែប្រួល អាកាសធាតុ និងពាណិជ្ជកម្ម និងកសាងយុទ្ធសាស្ត្រសកម្មភាពរ៉ែ ដែលនឹងជួយដល់អ្នកពាក់ព័ន្ធទាំងអស់។ ទន្ទឹមនឹងនេះ កម្រងទិន្នន័យស្តីពីជំនួយអភិវឌ្ឍន៍ផ្លូវការ ដែលឃ្លាំមើលជំនួយនានាដល់កម្ពុជា ក៏ត្រូវបានពង្រីកដើម្បីរួមបញ្ចូលអង្គការមិនមែនរដ្ឋាភិបាលផងដែរ។

ដោយទទួលស្គាល់ការប្រែប្រួលអាកាសធាតុថាជាផ្នែកមួយដែលមានកំណើនការយកចិត្តទុកដាក់ យូអិនឌីភីបានផ្តល់ការគាំទ្រដល់រដ្ឋាភិបាល ដើម្បីបង្កើតកិច្ចផ្តួចផ្តើមជាយុទ្ធសាស្ត្រលើគោលនយោបាយ និងប្រសិទ្ធភាពជំនួយនៅក្នុងផ្នែកនេះ។ នាយកដ្ឋានប្រែប្រួលអាកាសធាតុនៅក្នុងក្រសួងបរិស្ថាន សម្រេចបាននូវការវិភាគលក្ខខណ្ឌគោល ដែលមានសារៈសំខាន់សម្រាប់ការរៀបចំយុទ្ធសាស្ត្រជាតិប្រែប្រួលអាកាសធាតុនៅក្នុងឆ្នាំ ២០១០។ នៅកម្រិតគោលនយោបាយការប្រែប្រួលអាកាសធាតុ ត្រូវបានធ្វើសមាហរណកម្មជាលក្ខណៈប្រព័ន្ធទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម។ គួរកត់សំគាល់ផងដែរថា កម្ពុជាបានរៀបចំវេទិកាជាតិលើកដំបូងរបស់ខ្លួនស្តីពីការប្រែប្រួលអាកាសធាតុកាលពីខែ តុលា ដោយមាននាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្វើជាអធិបតីនៅក្នុងពិធីបើក និងមានការចូលរួមពីអ្នកកសាងគោលនយោបាយ មន្ត្រីនានា អ្នកជំនាញការបរទេស ដៃគូអភិវឌ្ឍន៍ សមាជិកសង្គមស៊ីវិល និងនិស្សិត សរុបចំនួនជាង ៣៥០ នាក់។

យើងក៏បានរួមចំណែកនៅក្នុងវិស័យផ្សេងទៀតជាច្រើនផងដែរគឺ អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ការកាត់បន្ថយភាពក្រីក្រ និង បរិស្ថាននិងថាមពល។ វិភាគទានទាំងនេះ មានចែងលំអិតនៅក្នុងផ្នែកនានាខាងក្រោមនេះ។

ទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងជនកម្ពុជាទាំងអស់ ដែលបានធ្វើឱ្យបទពិសោធន៍របស់ខ្ញុំកាន់តែមានភាពសំបូរបែប និងប្រកបដោយផ្លែផ្កាល្អ។

ចូ ស្ក័យើរ

នាយកការិយាល័យប្រចាំនៅកម្ពុជា

រូបថតលើក្របមុខ : យូអិនឌីភី/ដា រ៉ាសេង

*អ្នកសម្របសម្រួលថ្នាក់ភូមិចំនួនបីរូបកំពុងដឹកនាំកិច្ចសន្ទនាសហគមន៍មួយលើបញ្ហាយេនឌ័រ ដែលរួមបញ្ចូលអំពីអំពើហិង្សាក្នុងគ្រួសារផង នៅភូមិពូត្រុំ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី*

# មាតិកា


| | |
|---|---|
| ទិដ្ឋភាពរួមឆ្នាំ ២០០៩ | ២ |
| តើយើងធ្វើការបែបណា | ៣ |
| អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ | ៥ |
| ការកាត់បន្ថយភាពក្រីក្រ | ១៣ |
| បរិស្ថាន និងថាមពល | ២១ |
| ធ្វើការជាមួយគ្នា | ២៨ |
| ម្ចាស់ជំនួយ | ២៩ |
| លទ្ធផល - ការចំណាយទៅតាមវិស័យនៃប្រធានបទ | ២៩ |
| ពាក្យបំព្រួញ | ២៩ |


## ទិន្នន័យសំខាន់ៗអំពីកម្ពុជា

| | |
|---|---|
| ចំនួនប្រជាជននៅក្នុងឆ្នាំ ២០០៨ | ១៣.៤ លាននាក់[១] |
| អត្រាកំណើនចំនួនប្រជាជនប្រចាំឆ្នាំ ១៩៩៨-២០០៨ | ១,៥៤%[១] |
| ផលិតផលក្នុងស្រុកសរុប ឆ្នាំ ២០០៩ (ប៉ាន់ស្មាន) | ១០.៩៤ ពាន់លានដុល្លាអាមេរិក[២] |
| កំណើនផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំ ២០០៩ (ប៉ាន់ស្មាន) | ០,១%[៣] |
| ផលិតផលក្នុងស្រុកសរុបក្នុងម្នាក់ៗ នៅឆ្នាំ ២០០៩ (ប៉ាន់ស្មាន) | ៧៦៩ ដុល្លា[២] |
| ភាពក្រីក្រ (%នៃចំនួនប្រជាជននៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ) ឆ្នាំ ២០០៧ | ៣០,១%[៤] |
| អាយុកាលមធ្យមពេលកើត (បុរស/ស្ត្រី ប៉ាន់ស្មាន) ឆ្នាំ ២០០៨ | ៦០,៥/៦៤,៣[១] |
| អត្រាអក្ខរភាពមនុស្សពេញវ័យ (ក្នុងចំណោមមនុស្សអាយុ ១៥ឆ្នាំ និងអាយុ ច្រើនជាងនេះ បុរស/ស្ត្រី) ឆ្នាំ ២០០៨ | ៨៥,១%/៧០,៩%[១] |
| អត្រាមរណភាពកុមារ អាយុក្រោម ៥ ឆ្នាំ (ប៉ាន់ស្មានក្នុង ១០០០ កំណើតរស់) ឆ្នាំ ២០០៨ | ៩០[៥] |
| កុមារដែលត្រូវបានចាត់ទុកថាទទួលអាហារូបត្ថម្ភមិនគ្រប់គ្រាន់ គិតតាមទម្ងន់និងអាយុ ឆ្នាំ ២០០៨ | ២៨,៨%[៦] |
| អត្រាមរណភាពមាតា ក្នុងកំណើតរស់ ១០,០០០ នាក់ (ប៉ាន់ស្មាន) ឆ្នាំ ២០០៨ | ៤៦១[១] |
| អត្រាប្រេវ៉ាឡង់ប៉ាន់ស្មាននៃមនុស្សពេញវ័យផ្ទុកមេរោគអេដស៍ (អាយុ ១៥-៤៩ ឆ្នាំ ប៉ាន់ស្មាន) ឆ្នាំ ២០០៩ | ០,៧%[៧] |
| គ្រួសារមានលទ្ធភាពប្រើប្រាស់ប្រភពទឹកស្អាតជាងមុន (ទីក្រុង/ជនបទ) ២០០៨ | ៧៦%/៤១%[១] |
| ជនស៊ីវិលរងគ្រោះពីគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (ប្រចាំឆ្នាំ) ឆ្នាំ ២០០៩ | ២៤៤[៨] |
| ជំនួយអភិវឌ្ឍន៍ផ្លូវការ | ៩៨៩.៥ លានដុល្លាអាមេរិក[៩] |

*១. ជំរឿនពលរដ្ឋកម្ពុជាឆ្នាំ ២០០៨ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ http://www.nis.gov.kh/ ២. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ www.mef.gov.kh/macroeconomic.php ៣. សុន្ទរកថាដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១០: www.cnv.org/kh/ ៤. ការអង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជា ឆ្នាំ ២០០៧ : www.nis.gov.kh/index.php/statisticts/survey/cses ៥. UNICEF: www.unicef.org/infoby country/cambodia_statistics.html ៦. ការអង្កេតនរវិទ្យាកម្ពុជា ២៥ ទំព័រ ៧. មជ្ឈមណ្ឌលជាតិកំចាត់មេរោគអេដស៍/ជម្ងឺអេដស៍ រោគសើរស្បែក និងជម្ងឺកាមរោគ ក្រសួងសុខាភិបាល (២០០៧) របាយការណ៍ អំពីសិក្ខាសាលាឯកភាពមតិ: ការប៉ាន់ស្មាន និងការព្យាករណ៍អំពីមេរោគអេដស៍នៅកម្ពុជា ឆ្នាំ ២០០៦-២០១២ data.unaids.org/pub/Report/2008/Cambodia_hiv_estimation_report_2006_en.pdf ៨. ប្រព័ន្ធព័ត៌មានអំពីជនរងគ្រោះពីគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះរបាយការណ៍ប្រចាំខែកុម្ភៈ: www.cmac.gov.kh/ ៩. របាយការណ៍ប្រសិទ្ធភាពជំនួយនៅកម្ពុជា ទំព័រ ១*

### គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

១. លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និងភាពអត់ឃ្លាន

២. សម្រេចឱ្យបានជាទូទៅការអប់រំមូលដ្ឋានរយៈពេល ៩ ឆ្នាំ

៣. លើកកំពស់សមភាពយេនឌ័រ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី

៤. កាត់បន្ថយអត្រាមរណភាពកុមារ

៥. លើកកំពស់សុខភាពមាតា

៦. ប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ជំងឺអេដស៍ គ្រុនចាញ់ និងជំងឺដទៃទៀត

៧. ធានាចីរភាពបរិស្ថាន

៨. បង្កើតភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍន៍

៩. ការដោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការសង្គ្រោះជនរងគ្រោះ

# ទិដ្ឋភាពរួមឆ្នាំ ២០០៩



*យូអិនឌីភីគាំទ្រកម្ពុជាក្នុងការស្វែងរកដំណោះស្រាយផ្ទាល់ខ្លួន តបនឹងការប្រឈមនៃការអភិវឌ្ឍជាតិ និងពិភពលោក។*
*(យូអិនឌីភី/អ៊ីសាបែល លេសេរ)*

នៅក្នុងឆ្នាំ ២០០៩ យូអិនឌីភីនៅកម្ពុជាបានរួមវិភាគទានជាសំខាន់ទៅក្នុងការអភិវឌ្ឍដែលផ្តោតលើជនក្រីក្រ ដោយគាំទ្រដល់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ការកាត់បន្ថយភាពក្រីក្រ និងនិរន្តរភាពបរិស្ថាន។ ចំណុចលេចធ្លោនានារួមមាន ការជួយកសាងសម្ព័ន្ធភាពសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ការលើកទឹកចិត្តដល់រដ្ឋាភិបាលឱ្យមានលក្ខណៈឆ្លើយតបតាមរយៈវិមជ្ឈការ និងការជម្រុញឱ្យសភាចូលរួមប្រឡូកជាមួយប្រជាពលរដ្ឋ។ យូអិនឌីភីបានជួយរដ្ឋាភិបាលក្នុងការរួមចំណែករបស់ខ្លួន ក្នុងកិច្ចប្រឹងប្រែងអន្តរជាតិលើការដោះមីន ក្នុងបញ្ហាឱនភាពដី ការគ្រប់គ្រងសារធាតុគីមី សារធាតុបំផ្លាញស្រទាប់អូហ្សូន និងក្នុងប្រសិទ្ធភាពជំនួយ។ កិច្ចប្រឹងប្រែងនានាបានផ្តោតលើការអភិវឌ្ឍពាណិជ្ជកម្ម និងការបង្កើតឧស្សាហកម្មនានា និងជម្រុញឱ្យមានជម្រើសជំនួសនៅក្នុងរបរចិញ្ចឹមជីវិត ដែលជួយថែរក្សាជីវៈចម្រុះ និងធនធានធម្មជាតិ។ ការងាររបស់យូអិនឌីភី មានរាប់ចាប់ពីការផ្តល់យោបល់ខាងគោលនយោបាយ រហូតដល់ការបង្កើតសហគមន៍ជួយខ្លួនឯង ដែលអាចឱ្យគ្រួសារនានាកែលម្អការរស់នៅរបស់ខ្លួន។

ក្នុងផ្នែកអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ យោបល់ខាងគោលនយោបាយ បានរួមចំណែកដល់ការរៀបរៀងសេចក្តីព្រាងកម្មវិធីជាតិរយៈពេល ១០ ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហើយមន្ត្រី និងតំណាងនានាជាច្រើនពាន់នាក់ បានទទួលការបណ្តុះបណ្តាល ដើម្បីអាចឱ្យពួកគេអនុវត្តមុខនាទីថ្មីរបស់ខ្លួន។ វេទិកានានាដែលចាត់ចែងឡើងដោយសមាគមរដ្ឋាភិបាលមូលដ្ឋាន បានលើកកង្វល់នៅមូលដ្ឋានទៅដល់រដ្ឋាភិបាល។ សមាជិកសភាបានជួបជាមួយប្រជាពលរដ្ឋនៅទូទាំងប្រទេស និងបានអភិវឌ្ឍន៍ជំនាញ សម្រាប់អនុវត្តតួនាទីជាតំណាង ការតាក់តែងច្បាប់ និង ការត្រួតពិនិត្យ។ វិជ្ជាជីវៈសារព័ត៌មានប្រកបដោយតុល្យភាព បានលើកទឹកចិត្តឱ្យមានការជជែកវែកញែកលើបញ្ហាផ្សេងៗនានា។ សមភាពយេនឌ័រត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីវិមជ្ឈការ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម។ ប្រព័ន្ធដោះស្រាយទំនាស់ក្រៅតុលាការ បានជួយក្រុមពលរដ្ឋទន់ខ្សោយឱ្យទទួលបានយុត្តិធម៌កាន់តែច្រើនជាងមុន។

ដើម្បីគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រ ឧស្សាហកម្មសំខាន់ៗដែលមានសក្តានុពលសម្រាប់ការនាំចេញ ត្រូវបានពង្រឹងដើម្បីកម្ពុជាអាចទាញយកផលចំណេញពីសមាហរណកម្មរបស់ខ្លួនទៅក្នុងប្រព័ន្ធពាណិជ្ជកម្មពិភពលោក។ យូអិនឌីភី និងទីភ្នាក់ងារចំនួនបីផ្សេងទៀតនៃ អ.ស.ប បានជួយសង្គ្រោះឡើងវិញនូវឧស្សាហកម្មដែលមានលក្ខណៈច្នៃប្រឌិតនានា ដែលនឹងជួយថែរក្សាបេតិកភ័ណ្ឌវប្បធម៌របស់កម្ពុជា។ ការវិភាគអំពីបញ្ហាសំខាន់ៗ ដែលរួមទាំងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា និង ឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុពិភពលោកមកលើមូលដ្ឋាន បានរួមចំណែកធ្វើឱ្យការពិភាក្សាជុំវិញរឿងនេះ កាន់តែមានការយល់ដឹងច្រើនឡើង។ ការសិក្សាមួយអំពីការរីកចម្រើនក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា បានជួយធ្វើអត្តសញ្ញាណគម្លាតខាងទិន្នន័យដែលរួមចំណែកក្នុងការវាយតម្លៃរបស់រដ្ឋាភិបាលផ្ទាល់ក្នុងឆ្នាំ ២០១០។ ការងារបញ្ច្រាបជំនួយបរទេស បានជួយដៃគូអភិវឌ្ឍន៍នានាក្នុងការបន្សុីជំនួយរបស់ពួកគេ។ ការដោះមីន បានរំដោះដីទំហំ ៧,៨១ គម$^{២}$ សម្រាប់ជាប្រយោជន៍ដល់ច្រើនជាង ៤០.០០០គ្រួសារ។

រដ្ឋាភិបាល និងម្ចាស់ជំនួយ បានរួមគ្នាបង្កើតជាសម្ព័ន្ធភាពមួយដោយមានការគាំទ្រពីយូអិនឌីភី ដើម្បីជួយកម្ពុជាប្រយុទ្ធប្រឆាំងការប្រែប្រួលអាកាសធាតុ និង បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ការគ្រប់គ្រងដី ដោយមាននិរន្តរភាពកំពុងបន្ត ដើម្បីបញ្ឈប់ឱនភាពដីធ្លី។ នៅតាមភូមិ កិច្ចប្រឹងប្រែងនានាបានធ្វើឡើងដើម្បីបញ្ឈប់ការបាត់បង់ព្រៃឈើ បង្កើតសហគមន៍នេសាទ និងការពារព្រៃកោងកាង និងតំបន់ឆ្នេរសមុទ្រ។ កម្ពុជារួមចំណែកក្នុងកិច្ចប្រឹងប្រែងអន្តរជាតិ ដើម្បីការពារស្រទាប់អូហ្សូន និងបានលើកអនុសាសន៍ឱ្យមានការប្រើប្រាស់សារធាតុគីមីតាមវិធីដែលនឹងជួយកាត់បន្ថយឥទ្ធិពលប្រកបដោយគ្រោះថ្នាក់។ ទាក់ទងនឹងតំបន់សំខាន់ៗខាងជីវៈចម្រុះ យូអិនឌីភី បានធ្វើការលើកកំពស់ឱ្យមានការកសាងផែនការប្រើប្រាស់ដីធ្លី តាមបែបផែនដែលមានការចូលរួមការកំណត់តំបន់គ្រប់គ្រង និងព្រំប្រទល់។ អ្នកភូមិបានទទួលយករបរចិញ្ចឹមជីវិត ដូចជា អេកូទេសចរណ៍ ដែលកាត់បន្ថយសម្ពាធរបស់មនុស្សមកលើធនធានធម្មជាតិ។

# តើយើងធ្វើការបែបណា

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ជាទីភ្នាក់ងារមួយក្នុងចំណោមទីភ្នាក់ងារ ស្ថាប័នមូលនិធិ និងកម្មវិធីចំនួន ២៣ របស់ អ.ស.ប ដែលប្រតិបត្តិការនៅកម្ពុជា ក្រោមក្របខ័ណ្ឌរួមមួយនៃប្រព័ន្ធអ្នកសម្របសម្រួល អ.ស.ប ប្រចាំនៅក្នុងប្រទេសដែលធ្វើការដើម្បីធានាថា សកម្មភាពរបស់ អ.ស.ប បំពេញគ្នាទៅវិញទៅមក និងមិនត្រួតគ្នា។ យូអិនឌីភីនៅកម្ពុជា ផ្ដោតការងាររបស់ខ្លួនលើការលើកកំពស់អភិបាលកិច្ច តាមបែបប្រជាធិបតេយ្យ កាត់បន្ថយភាពក្រីក្រដោយផ្ទាល់ និងគ្រប់គ្រងបរិស្ថាន និងថាមពល សម្រាប់ការអភិវឌ្ឍដោយចីរភាព។ យូអិនឌីភី ធ្វើការដើម្បីការពារសិទ្ធិមនុស្ស និងពង្រឹងសិទ្ធិអំណាចរបស់ស្ត្រី។ អាទិភាពមួយដែលមានលក្ខណៈអន្តរវិស័យគឺ ការអភិវឌ្ឍ សមត្ថភាព ដោយពង្រឹងសមត្ថភាពរបស់បុគ្គល អង្គការ និងសង្គម ដើម្បីសម្រេចគោលបំណងអភិវឌ្ឍន៍របស់ពួកគេ។

យូអិនឌីភី ធ្វើការក្រោមភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល អង្គការសហគមន៍ ទីភ្នាក់ផ្ដល់ជំនួយពហុភាគី ម្ចាស់ជំនួយទ្វេភាគី និងក្រុមហ៊ុនឯកជន។ ប្រមាណ ៨០% នៃជំនួយអភិវឌ្ឍន៍របស់ខ្លួនត្រូវបានអនុវត្តដោយស្ថាប័ននានារបស់ជាតិ ដូចជា សភា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងពាក់ព័ន្ធ។ នៅថ្នាក់ក្រោមជាតិ យូអិនឌីភីធ្វើការជាមួយមន្ទីរ និងអង្គភាពនានានៅថ្នាក់ខេត្ត ក្រុង ស្រុក និងឃុំ។ ក្នុងករណីខ្លះ យូអិនឌីភី អនុវត្តគម្រោងដោយខ្លួនឯងផ្ទាល់ផងដែរ។

ការអភិវឌ្ឍសមត្ថភាព ត្រូវបានធ្វើឡើងតាមទម្រង់ជាច្រើន: កំណែទម្រង់ស្ថាប័ន ការបង្កើតភាពជាអ្នកដឹកនាំ ការអប់រំ ការបណ្ដុះបណ្ដាល និងរៀនសូត្រ និងយន្តការគណនេយ្យភាព និងការបង្កើតសម្លេងរួមគ្នា។ ទីប្រឹក្សារបស់យូអិនឌីភី ធ្វើការជាមួយសមភាគីកម្ពុជា ដើម្បីផ្ដល់ការណែនាំបច្ចេកទេស ចាត់ចែងសន្និសីទ ទស្សនកិច្ចសិក្សា និងការបណ្ដុះបណ្ដាលជាផ្លូវការ ក៏ដូចជាការហ្វឹកហាត់ និងការណែនាំផ្ទាល់ផងដែរ។ អ្វីដែលបានផ្ដល់ឱ្យអាចជាជំនាញងាយៗ ដូចជាការចាត់ចែងការប្រជុំ ឬ ជំនាញស្មុគស្មាញដូចជា ការគ្រប់គ្រងថវិកាជាច្រើនលានដុល្លា នៅក្នុងរយៈពេលច្រើនឆ្នាំ។ មូលនិធិបានមកពីប្រភពចំនួនបី គឺថវិកាស្នូលពីយូអិនឌីភី (ប្រមាណ ៩ លានដុល្លា) ម្ចាស់ជំនួយធំៗ ដែលតាមធម្មតាជារដ្ឋាភិបាលថ្នាក់ជាតិ (២៥ ទៅ ៣០ លានដុល្លាក្នុងមួយឆ្នាំ) និង មូលនិធិដែលផ្ដល់សម្រាប់គម្រោងជាក់លាក់។

នៅឆ្នាំ ២០០៩ យូអិនឌីភីនៅកម្ពុជា បានជួលមនុស្សចំនួន ៣៩៣ នាក់ (បុគ្គលិកស្នូល និងបុគ្គលិកគម្រោង) និងបានជួលទីប្រឹក្សាចំនួន ១៦៤ នាក់ ក្នុងនោះ ៣០ នាក់ជាស្ត្រី។ បុគ្គលិកស្នូលមាន ៨៥ នាក់ (បុរស ៤៩ នាក់ និងស្ត្រី ៣៦ នាក់។ ដូចគ្នានេះដែរ អ្នកស្ម័គ្រចិត្ត អ.ស.ប បានធ្វើការជាទីប្រឹក្សាបច្ចេកទេស និងជំនាញការ គាំទ្រដល់កម្មវិធីរបស់យូអិនឌីភី។ ក្នុងនាមជាអង្គការមួយដែលនាំមុខដោយចំណេះដឹង យូអិនឌីភី បានប្ដេជ្ញាដើម្បីបន្តរៀនសូត្រ និងអភិវឌ្ឍន៍វិជ្ជាជីវៈ។ បុគ្គលិកត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការរៀនសូត្រ ដែលផ្ដល់វគ្គបណ្ដុះបណ្ដាលចំនួន ៣០០០ លើប្រធានបទជាច្រើន និងជាភាសាខុសៗគ្នា។ ដូចគ្នានេះដែរ យូអិនឌីភី បានចាត់ចែងឱ្យមានវគ្គរៀនសូត្រប្រចាំសប្ដាហ៍ និងគាំទ្រដល់បុគ្គលិកជាច្រើនឱ្យរៀនសូត្ររៀងៗខ្លួនផងដែរ។

ការចំណាយសរុបលើលទ្ធកម្មរបស់យូអិនឌីភី នៅកម្ពុជាក្នុងឆ្នាំ ២០០៩ មាន ៨,១ លានដុល្លា ដែលមានកំណើន ៨,១% ធៀបនឹងឆ្នាំ ២០០៨។ ការផ្ដល់សេវាកម្មវិជ្ជាជីវៈនិងជំនាញការដើម្បីពង្រឹងសមត្ថភាពជាតិ ចំណាយអស់ ២,១ លានដុល្លា ឬត្រូវជាប្រមាណ ២៦% នៃការចំណាយសរុប។ យូអិនឌីភី ក៏បានសម្រួលលទ្ធកម្មក្នុងនាមទីភ្នាក់ងារ អ.ស.ប នានាផងដែរ ដែលនាំឱ្យមានការផ្ដល់អាហារូបករណ៍ និងការចូលរួមរបស់ជនកម្ពុជាចំនួន ២០៧ នាក់ នៅក្នុងសិក្ខាសាលាក្រៅប្រទេស។

*អ្នកភូមិនៅភូមិជុំស្រី វាលទំនាបខាងជើង បោះឆ្នោតជ្រើសរើសគណៈកម្មការតំបន់ការពារធម្មជាតិរបស់ខ្លួន។ យូអិនឌីភីគាំទ្រដល់ការកសាងផែនការប្រើប្រាស់ដីតាមបែបផែននៃការចូលរួម ដើម្បីបង្កើតសន្តិសុខនៃរបរចិញ្ចឹមជីវិត និងថែរក្សាធនធានធម្មជាតិ។*
*(ក្រសួងបរិស្ថាន/សុខ វុធិន)*





# អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ

## ការប្រឈម

ជាប្រពៃណី កម្ពុជា ជាសង្គមមួយដែលពោរពេញដោយឋានានុក្រមសង្គម ហើយរដ្ឋគ្រប់គ្រងតាមបែបផែនប្រមូលផ្តុំអំណាច ដែលអ្នកក្រីក្រ និងក្រុមអ្នកទន់ខ្សោយមានឥទ្ធិពលតិចតួចបំផុតមកលើការសម្រេចនានា ដែលមានផលប៉ះពាល់លើអាយុជីវិតរបស់ពួកគេ។ សព្វថ្ងៃនេះ កម្ពុជាជារបបប្រជាធិបតេយ្យក្មេងខ្ចីមួយកំពុងបណ្តុះវប្បធម៌នយោបាយពហុបក្ស។ នៅក្នុងសង្គមទូទៅ ស្ត្រី ជនក្រីក្រ និងក្រុមជនជាតិដើមភាគតិច ប្រឈមនឹងការលំបាកនានាក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន។ រដ្ឋាភិបាល មានការប្តេជ្ញាធ្វើវិមជ្ឈការ និងវិសហមជ្ឈការ ដែលជាសរសរគ្រឹះនៃការអភិវឌ្ឍដែលគាំទ្រដល់ជនក្រីក្រ និងបានចាប់ផ្តើមកិច្ចការដ៏ធំក្នុងការផ្ទេរអំណាច និងមុខនាទីទៅថ្នាក់ខេត្ត ស្រុក និងឃុំ។ ចាប់តាំងពីការបោះឆ្នោតជាតិនៅ ឆ្នាំ ២០០៨ រួចមក វាហាក់ដូចជាមានការរឹតត្បិតច្រើនឡើងៗទៅលើលទ្ធភាពរបស់ពលរដ្ឋក្នុងការពិភាក្សាដេញដោលនានា។ ច្បាប់ស្តីពីបទបរិហាកេរ្តិ៍ និង ការផ្តល់ព័ត៌មានមិនពិត និងការញុះញង់ត្រូវបានប្រើប្រាស់កាន់តែញឹកញាប់ឡើង ហើយបញ្ហាចុះឈ្មោះអ្នកបោះឆ្នោត និងបណ្តឹងតវ៉ាក្នុងការបោះឆ្នោត និងដំណើរការឧទ្ធរណ៍ក៏នៅពុំបានដោះស្រាយឡើយ។

## ការឆ្លើយតបរបស់យូអិនឌីភី

យូអិនឌីភី ធ្វើការដើម្បីជួយអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យឱ្យចាក់ឫស និងដើម្បីលើកកំពស់ការយល់ដឹងអំពីសិទ្ធិ និងការទទួលខុសត្រូវក្នុងរបបប្រជាធិបតេយ្យ។ នៅឆ្នាំ ២០០៩ យូអិនឌីភី បានជួយបង្កើតប្រព័ន្ធថ្មីមួយនៃរដ្ឋាភិបាលថ្នាក់ក្រោមជាតិរបស់កម្ពុជា តាមរយៈការផ្តល់យោបល់អំពីរចនាសម្ព័ន្ធ និងដំណើរការនានា និងតាមរយៈការអភិវឌ្ឍជំនាញ និងចំណេះដឹងក្នុងចំណោមមន្ត្រីនានា។ យូអិនឌីភី បានគាំទ្រដល់សមាគម រដ្ឋាភិបាលមូលដ្ឋាន និងបានពង្រឹងសមត្ថភាពក្រុមប្រឹក្សានានា ក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍មូលដ្ឋានតាមវិធី ដែលឆ្លើយតបនឹងតម្រូវការរបស់ពលរដ្ឋ។ យូអិនឌីភី ក៏គាំទ្រឱ្យមានវិជ្ជាជីវៈសារព័ត៌មានប្រកបដោយតុល្យភាព និងបានលើកទឹកចិត្តឱ្យមានការចូលរួមរបស់ពលរដ្ឋ និងគណនេយ្យភាពជាសាធារណៈផងដែរ។ សមាជិកសភា បានជួបប្រាស្រ័យដោយផ្ទាល់ជាមួយពលរដ្ឋជាច្រើនពាន់នាក់ នៅតាមមណ្ឌលបោះឆ្នោត និងបានបង្កើនចំណេះដឹងពីអ្នកជំនាញលើបញ្ហានានា ដែលកំពុងប្រឈមចំពោះមុខសង្គមកម្ពុជាផងដែរ។ កង្វល់អំពីយេនឌ័រ ត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយ និងកម្មវិធីកំណែទម្រង់ ហើយការតស៊ូមតិ ការស្រាវជ្រាវ យោបល់ និងការបណ្តុះបណ្តាល បានជួយសម្របសម្រួលដល់កិច្ចប្រឹងប្រែងធ្វើឱ្យមានសមភាពខាងយេនឌ័រផងដែរ។ ប្រជាពលរដ្ឋដែលទន់ខ្សោយមានលទ្ធភាពកាន់តែច្រើនឡើងក្នុងការទទួលបានយុត្តិធម៌ តាមរយៈយន្តការដោះស្រាយទំនាស់នៅក្រៅប្រព័ន្ធតុលាការ ដែលអនុញ្ញាតឱ្យពួកគេ ដោះស្រាយបញ្ហានានាដែលរួមមានអំពើហិង្សាក្នុងគ្រួសារ និងទំនាស់ដីធ្លីផងនោះ កាន់តែមានប្រសិទ្ធភាព និងដោយចំណាយតិចផងដែរ។

### សមិទ្ធផលសំខាន់ៗនៅក្នុងឆ្នាំ ២០០៩

- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានអនុម័តអនុក្រឹត្យសារាចរថ្នាក់ក្រសួង គោលការណ៍ណែនាំ សេចក្តីជូនដំណឹង និងសេចក្តីសម្រេចនានាចំនួន ៣១ ដើម្បីចាប់ផ្តើមដាក់ឱ្យអនុវត្តច្បាប់ឆ្នាំ ២០០៨ ស្តីពីរដ្ឋបាលថ្នាក់ក្រោមជាតិ។ ភាគច្រើននៃកម្មវិធីជាតិរយៈពេល ១០ ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំជាសេចក្តីព្រាង។
- សម្ព័ន្ធភាពជាតិឃុំ/សង្កាត់ បានសម្របសម្រួលឱ្យមានវេទិកាចំនួន ២ នៅថ្នាក់តំបន់ ១១ នៅថ្នាក់ខេត្ត និង ៥៥ នៅថ្នាក់ស្រុក បានប្រមូលកង្វល់នានានៅមូលដ្ឋាន និងពាំនាំយកមកធ្វើការតស៊ូមតិនៅថ្នាក់ជាតិ។
- សមាជិកសភាបានធ្វើទស្សនកិច្ចចំនួន ១៣ លើក ទៅខេត្តចំនួន ១៧ បានរៀបចំឱ្យមានវេទិកាសាធារណៈចំនួន ៧ លើក ធ្វើទស្សនកិច្ចតាមហេដ្ឋារចនាសម្ព័ន្ធនានា ដូចជា គ្លីនិកសុខភាព និងពន្ធនាគារ បានសំណេះសំណាលជាមួយពលរដ្ឋ និងធ្វើការជាមួយមន្ត្រីមូលដ្ឋាន ដើម្បីរកដំណោះស្រាយសម្រាប់បញ្ហានៅមូលដ្ឋាន។
- កម្មវិធីសមធម៌ប្រចាំសប្តាហ៍ បានផលិតកម្មវិធីបច្ចុប្បន្នភាពចំនួន ៥២ លើក អំពីបញ្ហារសើបនានា សម្រាប់ ចាក់ផ្សាយតាម ស្ថានីយ៍ទូរទស្សន៍ជាតិ ទទក។
- កង្វល់ខាងផ្នែកយេនឌ័រត្រូវបានដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម (២០០៩-២០១៣) ។
- សមាមាត្រនៃស្ត្រីកាន់កាប់តំណែងក្នុងរដ្ឋាភិបាលបានកើនឡើងពី ៣២% នៅឆ្នាំ ២០០៨ ដល់ ៣៤% នៅឆ្នាំ ២០០៩។
- យន្តការថ្មីសម្រាប់ដោះស្រាយទំនាស់នៅក្រៅប្រព័ន្ធតុលាការ ត្រូវបានពង្រឹង និងពង្រីកគណៈកម្មការដោះស្រាយទំនាស់ថ្នាក់ឃុំចំនួន ៣៦ ថែមទៀតត្រូវបានបង្កើតឡើង ធ្វើឱ្យចំនួនសរុបឡើងដល់ ៥៦។
- ករណីចំនួន ១៩៦៨ ត្រូវបាននាំមកដោះស្រាយនៅមណ្ឌល សេវាកម្មយុត្តិធម៌ ក្នុងនោះ ៧៩២ ត្រូវបានសម្រុះសម្រួល ដោយជោគជ័យ។
- វេទិកាតុសន្តិភាព បានជួយដោះស្រាយទំនាស់ដីធ្លី ដែលពាក់ព័ន្ធ នឹងជនជាតិដើមភាគតិច។

*រូបនៅម្ខាងទំព័រ : និស្សិតសកលវិទ្យាល័យពិភាក្សានៅក្នុងទស្សនកិច្ចមួយនៅវិមានសភាអំពីអ្វីដែលធ្វើឱ្យប្រជាធិបតេយ្យដំណើរការបានល្អ។ (យូអិនឌីភី/ឡាយ ចាន់សុខ)*

# រដ្ឋបាលមូលដ្ឋានកាន់តែរឹងប៉ឹងបង្កើនការឆ្លើយតប និងគណនេយ្យភាព

*"ខ្ញុំទទួលបានចំណេះដឹង និងរៀនសូត្រអំពីជំនាញដែលខ្ញុំអាចយកទៅប្រើប្រាស់ក្នុងការងារប្រចាំថ្ងៃ និងចែករំលែកជាមួយជនបង្គោល ខាងការតាមដាន និងវាយតម្លៃ។ ប្រសិនបើគ្មានជំនាញ និងចំណេះដឹងទេនោះ បុគ្គលិកថ្នាក់ខេត្តរបស់យើងមិនអាចផ្តល់សេវាកម្មដល់ពលរដ្ឋនៅមូលដ្ឋាន ប្រកបដោយប្រសិទ្ធិភាពតាមតែយើងចង់បាននោះឡើយ"*
*លោកស្រី ជួប ខឹមនិក អ្នកឈានមុខក្នុងការបណ្តុះបណ្តាលលើការតាមដាន និងវាយតម្លៃគម្រោងរដ្ឋាភិបាលមូលដ្ឋានពីខេត្តប៉ៃលិន។*

រដ្ឋាភិបាលបានកំណត់វិមជ្ឈការ និងវិសហមជ្ឈការអំណាចរដ្ឋាភិបាល ជាសរសរគ្រឹះនៃយុទ្ធសាស្ត្រ អភិវឌ្ឍន៍របស់ខ្លួន។ យូអិនឌីភី គាំទ្រគោលនយោបាយនេះ សម្រាប់ជាមធ្យោបាយលើកកំពស់ការអភិវឌ្ឍ ផ្តល់សិទ្ធិអំណាចដល់អ្នកក្រ និងធ្វើឱ្យមន្ត្រីជាប់ឆ្នោតកាន់តែមានគណនេយ្យភាពជាងមុន។ ដំណើរការនេះបានឆ្លងកាត់របត់មួយនៅក្នុងឆ្នាំ ២០០៨ តាមរយៈការអនុម័តច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលផ្តល់នូវចក្ខុវិស័យអំពីរដ្ឋបាលថ្នាក់ក្រោមជាតិនៅបីលំដាប់។ ច្បាប់នេះ បានចូលជាធរមាននៅក្នុងឆ្នាំ ២០០៩ នៅពេលដែលសមាជិកក្រុមប្រឹក្សានៅរដ្ឋបាលមូលដ្ឋានចំនួន ១.៦២១ ដែលហៅថា ឃុំ នៅតាមជនបទ និង សង្កាត់នៅតាមទីក្រុង បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្រុង/ស្រុក/ខណ្ឌចំនួន ១៩៣ និង ក្រុមប្រឹក្សាខេត្ត/រាជធានីចំនួន ២៤។

ក្រោមភាពជាដៃគូជាមួយ SIDA, DFID និង EU យូអិនឌីភី ធ្វើការជាមួយក្រសួងចំនួន ១០ នៅថ្នាក់ជាតិ ក៏ដូចជាក្រុមប្រឹក្សាជាប់ឆ្នោតនិងមន្ត្រីតែងតាំងនានានៅថ្នាក់ខេត្ត ស្រុក និងឃុំផងដែរ។ ដៃគូទាំងនេះ គាំទ្រដល់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) និងលេខាធិការដ្ឋាននៃគណៈកម្មាធិការនេះ ដែលមានភារៈទទួលខុសត្រូវក្នុងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ គណៈកម្មាធិការនេះ និង លេខាធិការដ្ឋានជួយដល់ស្ថាប័ននានារបស់រដ្ឋាភិបាលនៅក្នុងការធ្វើអន្តរកម្មឈានទៅរកប្រព័ន្ធថ្មី ដោយគាំទ្រឱ្យមានការបណ្តុះបណ្តាលអំពីរចនាសម្ព័ន្ធ ប្រព័ន្ធតួនាទីនិងការទទួលខុសត្រូវ។ នៅឆ្នាំ ២០០៩ លេខាធិការដ្ឋាននៃ គ.ជ.អ.ប បានរៀបចំសេចក្តីព្រាង ភាគច្រើននៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងបានរៀបរៀងអនុក្រឹត្យ សារាចរថ្នាក់ក្រសួង (ប្រកាស) គោលការណ៍ណែនាំ សេចក្តីជូនដំណឹង និងសេចក្តីសម្រេចនានាចំនួន ៣១ ដើម្បីចាប់ផ្តើមអនុវត្តច្បាប់នេះ។ ដៃគូនានាក៏បានជួយក្រុមប្រឹក្សា និងមន្ត្រីនៅថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រងគម្រោងអភិវឌ្ឍន៍នានាស្របតាមគោលការណ៍នៃមូលនិធិវិនិយោគ អំពីបច្ចេកទេសរៀនសូត្រនៃដំណើរការអភិបាលកិច្ច ការត្រួតពិនិត្យ និងតម្លាភាពផងដែរ។ ទឹកប្រាក់ប្រមាណ ៨២ លានដុល្លា ពីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាត្រូវបានផ្តល់តាមរយៈយន្តការដែលគាំទ្រដោយយូអិនឌីភី សម្រាប់ការសម្របសម្រួលកម្មវិធី ការកសាងគោលនយោបាយ និងប្រតិបត្តិការនៅថ្នាក់ក្រោមជាតិ។



*ផ្លូវថ្នល់ និងស្ពាន ផ្តល់ឱ្យពលរដ្ឋនៅជនបទនូវលទ្ធភាពប្រសើរជាងមុនក្នុងការធ្វើដំណើរទៅផ្សារ និងស្វែងរកសេវាកម្មនានា កែលម្អការចិញ្ចឹមជីវិត និងកាត់បន្ថយភាពក្រីក្រ។ ការវិនិយោគត្រូវបានផ្តល់តាមរយៈរចនាសម្ព័ន្ធ និងប្រព័ន្ធដែលអនុម័តនៅថ្នាក់ជាតិ។*
*(យូអិនឌីភី/កែ មុនធិត)*

យូអិនឌីភី ធ្វើការជាដៃគូជាមួយ EU ដើម្បីគាំទ្រដល់សម្ព័ន្ធភាពជាតិឃុំ/សង្កាត់ ដែលធ្វើការដើម្បីបង្កើតក្រុមប្រឹក្សានៅមូលដ្ឋាន ពង្រឹងសមត្ថភាពរបស់ពួកគេឱ្យចេះធ្វើការនៅក្នុងរដ្ឋាភិបាល និងលើកកំពស់ការចែករំលែកចំណេះដឹង។ សម្ព័ន្ធភាពនេះមានអាសនៈអចិន្ត្រៃយ៍នៅក្នុងអនុគណៈកម្មាធិការ គ.ជ.អ.ប ដែលអនុញ្ញាតឱ្យពួកគេធ្វើការតស៊ូមតិនៅថ្នាក់ជាតិ អំពីអភិបាលកិច្ចនៅមូលដ្ឋាន។ នៅឆ្នាំ ២០០៩ សម្ព័ន្ធភាពនេះ បានចធ្វើវេទិកាក្នុងតំបន់ចំនួនពីរ ខេត្តចំនួន ១១ និង ស្រុកចំនួន ៥៥ ដើម្បីពាំនាំយកតម្រូវការនៅមូលដ្ឋានទៅឱ្យមន្ត្រីនៅថ្នាក់ជាតិដឹងឮ និងដើម្បីអនុញ្ញាតឱ្យសមាជិកក្រុមប្រឹក្សានានា បង្កើតបណ្តាញគាំទ្រគ្នាទៅវិញទៅមក។ ក្រសួងមហាផ្ទៃ និងសម្ព័ន្ធភាពនេះបានប្រកាស កម្មវិធីផ្តល់រង្វាន់ទម្លាប់ល្អៗដល់ក្រុមប្រឹក្សា ឃុំ/សង្កាត់ ដែលទទួលស្គាល់ការអនុវត្តការងារល្អៗរបស់រដ្ឋាភិបាលមូលដ្ឋាន។ សមាជិកសម្ព័ន្ធភាពនេះបានធ្វើទស្សនកិច្ចនៅប្រទេសនេប៉ាល់ និងឥណ្ឌូនេស៊ី ដើម្បីសិក្សាអំពីសមាគមរដ្ឋបាលមូលដ្ឋាន និង ពិភាក្សាអំពីកិច្ចការផ្តល់សេវាកម្ម។

យូអិនឌីភី បានធ្វើការជាមួយការិយាល័យកសាងសមត្ថភាពនិងបណ្តុះបណ្តាលនៃនាយកដ្ឋានរដ្ឋបាល មូលដ្ឋាននៅក្នុងក្រសួងមហាផ្ទៃ ដើម្បីបង្កើតវគ្គបណ្តុះបណ្តាលចំនួន ៣៦ ក្នុងគោលដៅបំពាក់ឱ្យសមាជិកក្រុមប្រឹក្សា និង មន្ត្រីនានានូវសមត្ថភាពដើម្បីប្រតិបត្តិការនៅក្នុងប្រព័ន្ធថ្មីនេះ។ វគ្គបណ្តុះបណ្តាលចំនួន ៨.៦៤៤ សម្រាប់សិក្ខាកាមចំនួន ៣១៣.៥៧៣ នាក់ (បុរស ១៨៨.០២០, ស្ត្រី ១២៥.៧៣៣) បានធ្វើឱ្យចំនួនសរុបនៃអ្នកដែលបានទទួលការគាំទ្រពី យូអិនឌីភី ឡើងដល់ ៤.២៦២.៣៥៨ នាក់-ថ្ងៃ។ ប្រមាណ ៨៦% នៃវគ្គបណ្តុះបណ្តាលទាំងនេះ បានធ្វើឡើងនៅថ្នាក់ឃុំ។ ជិត ២៨% នៃវគ្គទាំងនេះ បានផ្តោតលើកិច្ចការសង្គម ១៧% លើប្រធានបទអំពីសេដ្ឋកិច្ចនិងកសិកម្ម ១១% អំពីការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន ៧% អំពីរដ្ឋបាល និងសន្តិសុខ និង ៥% អំពីការបញ្ជ្រាបយេនឌ័រ។ យូអិនឌីភី បានធ្វើការដើម្បីធានាថា ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និង សេវាកម្មនៅមូលដ្ឋាន ដោយរាប់ចាប់ពីផ្លូវថ្នល់ ស្ពាន និងការស្រោចស្រពរហូតដល់សាលារៀន និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានផ្តល់តាមរយៈយន្តការនានា ដែលលើកទឹកចិត្តឱ្យមានការចូលរួម និងលើកកំពស់គណនេយ្យភាព។ ទឹកប្រាក់សរុបចំនួន ៥៦ លានដុល្លា ត្រូវបានផ្តល់តាមរយៈមូលនិធិចំនួនបួនគឺ មូលនិធិឃុំ/សង្កាត់ (៤៩ លានដុល្លា) មូលនិធិវិនិយោគខេត្ត (២.៤លាន ដុល្លា) និងមូលនិធិសហប្រតិបត្តិការអន្តរឃុំ (១.៨៣ លានដុល្លា)។ យូអិនឌីភី បានគាំទ្រដល់ការចាត់ចែងមូលនិធិនេះ និងការអនុវត្តគម្រោងនានា តាមរយៈការបណ្តុះបណ្តាល

លើការណែនាំអំពីគម្រោង នីតិវិធីហិរញ្ញវត្ថុ ការសិក្សាលទ្ធភាពការធានាសមិទ្ធផល គម្រោងការកសាងផែនការលទ្ធកម្ម គណនេយ្យភាពការតាមដាន និងការធ្វើសេចក្ដីរាយការណ៍។ ឧបសគ្គនានាត្រូវបានដោះស្រាយ រីឯនីតិវិធីនានាត្រូវបានបន្សុីគ្នា ដូច្នេះមូលនិធិត្រូវបានផ្ទេរតាមអត្រាខ្ពស់ជាងនៅក្នុងឆ្នាំកន្លងទៅ ហើយគម្រោងកាន់តែមានលក្ខណៈឆ្លើយតបទៅនឹងតម្រូវការនៅមូលដ្ឋាន។ សក្ដានុពលសម្រាប់យូអិនឌីភីក្នុងការគាំទ្រឱ្យមាន កំណែលម្អការអនុវត្តគម្រោងដោយប្រើប្រាស់ក្របខ័ណ្ឌ គ.ជ.អ.ប ត្រូវបានបង្ហាញតាមរយៈការប្រៀបធៀបគម្រោង និងហេដ្ឋារចនាសម្ព័ន្ធចំនួន ២១ ដែលមានទឹកប្រាក់ដល់ ៦៣ លានដុល្លា ដែលបានពីការវិនិយោគរបស់រដ្ឋាភិបាល និង ម្ចាស់ជំនួយចំនួន ១៥។ អត្រានៃការផ្ទេរ និងបញ្ជូនសាច់ប្រាក់សម្រាប់គម្រោងនានា ដែលទទួលការគាំទ្រពេញលេញពី យូអិនឌីភី មាន ៣៥% ខ្ពស់ជាងគម្រោងដែលបានទទួលការគាំទ្រត្រឹមតែមួយផ្នែកពីយូអិនឌីភី។

ដើម្បីលើកកំពស់ប្រសិទ្ធិភាពជំនួយ យូអិនឌីភី បានគាំទ្រឱ្យមានសិក្ខាសាលាសមាហរណកម្មប្រចាំឆ្នាំ ដែលធ្វើឡើងនៅក្នុងស្រុកទាំងអស់ ដែលមានការចូលរួមពីក្រុមប្រឹក្សាឃុំ/សង្កាត់ទាំងអស់ និងអ្នកគាំទ្រនានា ដែលរួមទាំងមន្ទីរវិស័យនានានៃក្រសួងនៅថ្នាក់ជាតិ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល។ នៅឆ្នាំ ២០០៩ សិក្ខាសាលានានា បានចាត់ចែងឱ្យមានកិច្ចព្រមព្រៀងរយៈពេលមួយឆ្នាំចំនួន ៤២.១៣៦ រវាងក្រុមប្រឹក្សា និងអ្នកគាំទ្រគម្រោងសម្រាប់អនុវត្តនៅឆ្នាំ ២០១០ ជម្រុញឱ្យមានការឆ្លើយតប និងគណនេយ្យភាពពីសំណាក់អ្នកគាំទ្រ។ ពីឆ្នាំ ២០០៨ ដល់ ២០០៩ ភាគរយនៃកិច្ចព្រមព្រៀងដែលមានការឆ្លើយតបដោយផ្ទាល់ទៅនឹងអាទិភាពរបស់ឃុំបានកើនឡើងពី ៣៥% ដល់ ៤៦% ចំណែកការអនុវត្តបានកើនឡើង ពី ៧៣% ដល់ ៨៣%។ យូអិនឌីភី បានគាំទ្រឱ្យមានការរៀបរៀងសៀវភៅ ទិន្នន័យថ្នាក់ស្រុកចំនួន ១៩៣ និងសៀវភៅទិន្នន័យថ្នាក់ខេត្ត/រាជធានីចំនួន ២៤ ដែលប្រមូលផ្ដុំទិន្នន័យពីប្រភពខុសៗគ្នាជាច្រើន ដែលអនុញ្ញាតឱ្យមានការកសាងផែនការ និងការគ្រប់គ្រងបានប្រសើរជាងមុន។ យូអិនឌីភី បានគាំទ្រដល់ការកែលម្អកម្រងទិន្នន័យព័ត៌មានគម្រោង សម្រាប់តាមដានគម្រោងដែលគាំទ្រដោយមូលនិធិឃុំ/សង្កាត់ និងផ្សារភ្ជាប់ជាមួយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ/សង្កាត់។ សមត្ថភាពបច្ចេកវិទ្យាព័ត៌មាន ត្រូវបានបង្កើតឡើងនៅក្នុងស្រុក/ក្រុងទាំង ១៩៣ និងខេត្ត/រាជធានីទាំង ២៤។

## ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន ជួយកែលម្អគុណភាពនៃការរស់នៅក្នុងស្រុកដែលជាអតីតសមរភូមិ

នៅខេត្តបាត់ដំបង ដែលសន្តិភាពមិនទាន់កើតមានរហូតដល់ចុងទសវត្សរ៍ឆ្នាំ ១៩៩០ យូអិនឌីភី បានធ្វើការជាមួយ EU និងរដ្ឋាភិបាល ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធ និងផ្ដល់ការបណ្ដុះបណ្ដាលអំពីរបរចិញ្ចឹមជីវិត។ ការវិនិយោគនានាបានធ្វើឡើងនៅក្នុងស្រុកអតីតសមរភូមិចំនួនបួន ដោយប្រើប្រាស់រចនាសម្ព័ន្ធ និងប្រព័ន្ធដែលអនុម័ត ដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ សហគមន៍នានាបានចូលរួមនៅក្នុងការជ្រើសរើសទីតាំង និងផ្ទៀងផ្ទាត់ដំណើរការគម្រោង ដូច្នេះបានជួយពង្រឹងស្មារតីនៃភាពជាម្ចាស់នៅមូលដ្ឋាន។ គម្រោងនេះ បានសាងសង់ផ្លូវក្រាលគ្រួសក្រហមប្រវែង ៨១ គម ស្ពាន ចំនួន ១៧ បំពង់លូចំនួន ១២៨ កន្លែង និងទំនប់បង្ហៀរមួយ ដែលផ្ដល់ឱ្យគ្រួសារចំនួន ២៤.៩៤៥ នូវលទ្ធភាពប្រសើរជាងមុន ដើម្បីទៅសាលារៀន មណ្ឌលសុខភាព និងសេវាកម្មនានាផ្សេងទៀត និងធ្វើឱ្យកាន់តែងាយស្រួលដឹកជញ្ជូនផលិតផលទៅទីផ្សារ។ លើសពីនេះ អណ្ដូងចំនួន ១០៧ បានរំដោះគ្រួសារនានាពីទម្លាប់នៃការជញ្ជូនទឹកពីស្ទឹងដែលស្ថិតនៅឆ្ងាយ ដែលពួកគេធ្លាប់បានបន្ទោសថាជាមូលហេតុនាំឱ្យមានជម្ងឺ។ គណៈកម្មការគ្រប់គ្រងត្រូវបានបង្កើតឡើង ដែលមានប្រជាជនចំនួន ៨០៨ នាក់ (បុរស ៥៦៦, ស្ត្រី ២៤២) ចូលរួម។ សមាជិកគណៈកម្មការគ្រប់គ្រងអណ្ដូង បានរៀនសូត្រអំពីរបៀបថែទាំសំខាន់ៗ អនាម័យ និងការសំអាត និងបន្តបណ្ដុះបណ្ដាលអ្នកភូមិចំនួន ២.១១៣ នាក់ផ្សេងទៀត (បុរស ៨៩៥, ស្ត្រី ១២៣៨)។ សាលារៀនថ្មីចំនួន ១០ បានជួយកាត់បន្ថយចំនួនសិស្សក្នុងបន្ទប់រៀនមួយៗពី ៧០ មកត្រឹម ៥០ នាក់។ គណៈកម្មការសាលារៀនខ្លះបានចាប់ផ្ដើមប្រមូលវិភាគទាន សម្រាប់បំពេញចំណាយលើការថែទាំ និងបង្កើតសួនដំណាំផ្សេងៗ។ មណ្ឌលបណ្ដុះបណ្ដាលចំនួនពីរត្រូវបានកសាងឡើង ហើយស្ត្រីចំនួន ៤២ នាក់ បានទទួលការបណ្ដុះបណ្ដាលជំនាញកាត់ដេរ និង អ៊ុតសក់។ វាជាសេចក្ដីសង្ឃឹមមួយថា កិច្ចការនេះនឹងអាចជួយស្ត្រីក្នុងការស្វែងរកការងារធ្វើ ឬក៏ចាប់ផ្ដើមមុខរបរនៅមូលដ្ឋាន ដែលនឹងជួយកាត់បន្ថយនូវតម្រូវការរបស់ពួកគេ ក្នុងការធ្វើចំណាកស្រុកទៅកាន់ទីក្រុង និងទីប្រជុំជននានាដើម្បីស្វែងរកការងារធ្វើ។



*អណ្ដូងជួយកែលម្អសុខភាព និងកាត់បន្ថយពេលដែលគ្រួសារនានាត្រូវទៅដងទឹកនៅស្ទឹងដែលស្ថិតនៅឆ្ងាយពីភូមិ។ គណៈកម្មការគ្រប់គ្រងទឹករៀនសូត្រអំពីការថែទាំអណ្ដូង និងបណ្ដុះបណ្ដាលដល់អ្នកភូមិអំពីអនាម័យ និងការសំអាត។ (យូអិនឌីភី/ធូ វណ្ណៈ)*

*"យើងអាចជញ្ជូនពោតចេញពីចំការដោយងាយស្រួលជាងមុនច្រើនណាស់ ហើយអ្នកទិញក៏អាចយករថយន្តរបស់ខ្លួនចូលមកប្រមូលផលបានផងដែរ។ យើងអាចលក់ផលិតផលដោយថ្លៃខ្ពស់ជាងមុន។ នេះដោយសារមានផ្លូវ និងស្ពានល្អជាងមុន"*
*ជូ សាយុធ អាយុ ២៨ ឆ្នាំ កសិករដាំពោតនៅខេត្តបាត់ដំបង*



*អាជ្ញាធរប្រពៃណីក្នុងក្រុមជនជាតិដើមភាគតិច ខេត្តមណ្ឌលគិរី ជួបជាមួយសមាជិកសភា និងពិភាក្សាអំពីការលំបាកនានាដែលពួកគេប្រឈម ក៏ដូចជាអំពីវប្បធម៌ ប្រព័ន្ធរបបចិញ្ចឹមជីវិត និងគោលការណ៍ប្រពៃណីផងដែរ (រដ្ឋសភា)*

## សមាជិកសភាជួបប្រាស្រ័យជាមួយប្រជាជន និង កសាងជំនាញថ្មី

គន្លឹះសម្រាប់អភិបាលកិច្ចល្អ គឺសមត្ថភាពរបស់សភាក្នុងការធ្វើជាតំណាងឱ្យពលរដ្ឋ តាក់តែងច្បាប់ និង ត្រួតពិនិត្យស្ថាប័ននីតិប្រតិបត្តិនៃរដ្ឋាភិបាល។ យូអិនឌីភី គាំទ្ររដ្ឋសភា និងព្រឹទ្ធសភាក្នុងការអនុវត្តមុខនាទីទាំងនេះ និងជួយអគ្គលេខាធិការដ្ឋាននៃសភាទាំងពីរ និង លេខាធិការដ្ឋានសម្របសម្រួលបច្ចេកទេស (TCS) ក្នុងការផ្តល់សេវាដោយប្រសិទ្ធភាព។ នៅឆ្នាំ ២០០៩ សមាជិកសភាបានធ្វើបេសកកម្មនៅតាមមូលដ្ឋាន និងចាត់ចែងឱ្យមានវេទិកាសាធារណៈចូលរួមនៅក្នុងវេទិកានានាជាមួយក្រុមប្រឹក្សាឃុំ និងចូលរួមនៅក្នុងការផ្សព្វផ្សាយដល់យុវជន។ សមាជិកសភាបានពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ និងចែករំលែកយោបល់តបតាមរយៈការពិភាក្សាជាមួយស្ថាប័ននីតិប្រតិបត្តិ។ សមាជិកសភាក៏បង្កើនចំណេះដឹង និងជំនាញតាមរយៈសិក្ខាសាលា និងកិច្ចប្រជុំនានា និងចែករំលែកបទពិសោធន៍ជាមួយសមាជិក សភាមកពីប្រទេសដទៃផងដែរ។

បេសកកម្មទាំង ១៣ លើក មានការចូលរួមពីសមាជិកសមាជិកាសភាចំនួន ១០៩ រូប (បុរស ៨២,ស្ត្រី ២៧) នៅក្នុងខេត្តចំនួន ១៧ ដើម្បីពិនិត្យមើលការផ្សព្វផ្សាយអំពីច្បាប់ ដែលរួមទាំងច្បាប់នានាដែលទាក់ទងនឹងមេរោគអេដស៍/ជម្ងឺអេដស៍ ជនពិការ និងអំពើហិង្សាក្នុងគ្រួសារផងដែរ។ អ្នកតាក់តែងច្បាប់ បានជួបនៅក្នុងវេទិកាសាធារណៈចំនួនប្រាំពីរ ស្តីពីបញ្ហានានា ដែលរួមមានទំនាស់ដីធ្លី និងការជួញដូរមនុស្ស និងបានធ្វើទស្សនកិច្ចតាមពន្ធនាគារ មណ្ឌលបន្សាបថ្នាំញៀន និងមណ្ឌលថែរក្សាស្ត្រីមានផ្ទៃពោះផងដែរ។ សមាជិកសភាបានពិនិត្យមើលដំណោះស្រាយ និងលើកស្នើឱ្យមានចំណាត់ការកែលម្អនានា ដែលរួមមានទាំងការបង្កើតមូលនិធិអភិវឌ្ឍន៍ស្ត្រីផងដែរ។ ទស្សនកិច្ចមួយទៅខេត្តមណ្ឌលគិរី បានជួយសមាជិកសភាឱ្យយល់ដឹងថែមទៀតអំពីវប្បធម៌ និងការរស់នៅរបស់ជនជាតិដើមភាគតិច ហើយមេដឹកនាំជនជាតិដើមចំនួន ២៣ រូប បានមកទស្សនកិច្ចនៅសភា ដែលអនុញ្ញាតឱ្យពួកគេទាមទារដល់សមាជិកសភាឱ្យពង្រឹងគណនេយ្យភាពលើចំណាត់ការរបស់ខ្លួនដូចដែលបានសន្យា។ យូអិនឌីភី បានគាំទ្រឱ្យមានវេទិកាថ្នាក់តំបន់ចំនួនពីរលើកស្តីពីអភិបាលកិច្ចនៅមូលដ្ឋាន ដែលចាត់ចែងឡើងដោយសម្ព័ន្ធភាពជាតិឃុំ/សង្កាត់។ វេទិកាទាំងនេះ ដែលបានជួយឱ្យក្រុមប្រឹក្សាមូលដ្ឋាន បានជួបជាមួយសមាជិកសភាចំនួន ៦៤ រូប បានធ្វើអត្តសញ្ញាណការប្រឈមនានា ដូចជា មូលនិធិសម្រាប់សកម្មភាពនៅថ្នាក់ឃុំ និងការរើសអើងប្រឆាំងសមាជិកក្រុមប្រឹក្សាដែលជាស្ត្រី។ សេចក្តីព្រាងច្បាប់ស្តីពីការសុំកូនចិញ្ចឹមឆ្លងប្រទេស និងសេចក្តីកែសម្រួលក្រមព្រហ្មទណ្ឌ ត្រូវបានពិភាក្សាក្នុងសវនាការនានាដែលមានការចូលរួមដោយចៅក្រម មេធាវី និងអ្នកសារព័ត៌មានក៏ដូចជាតំណាងមកពីស្ថានទូត និងសង្គមស៊ីវិលផងដែរ។ កិច្ចប្រជុំមួយនៃស្ត្រីជាមេដឹកនាំ បានទទួលការគាំទ្រពីយូអិនឌីភី ហើយសហភាពអន្តរសភាបានបង្កើតជាកិច្ចព្រមព្រៀងបណ្តោះអាសន្នមួយ ដើម្បីបង្កើតក្រុមសមាជិកាសភានៅក្នុងស្ថាប័នសភាជាតិ។ ក្រមសីលធម៌មួយស្តីពីការអនុវត្តសម្រាប់សភាទាំងពីរ ត្រូវបានរៀបរៀងជាសេចក្តីព្រាង និងស្ថិតក្រោមការពិគ្រោះយោបល់នៅឡើយ។ យូអិនឌីភី បានគាំទ្រឱ្យមានវគ្គផ្តល់បទបង្ហាញនៅពេលព្រឹកស្តីពីបញ្ហាសំខាន់ៗមួយចំនួន។ សិក្ខាសាលាមួយត្រូវបានរៀបចំឡើងក្រោមកិច្ចសហការជាមួយសភាអូស្ត្រាលី ដែលអនុញ្ញាតឱ្យសមាជិកសភាចំនួន ៨៩ រូប បង្កើនការស្វែងយល់អំពីបច្ចេកទេសត្រួតពិនិត្យ។ សិក្ខាសាលាមួយដែលមានរយៈពេលមួយថ្ងៃស្តីពីប្រជាធិបតេយ្យ និងការអត់ឱនខាងនយោបាយ ត្រូវបានរៀបចំឡើងជាមួយសហភាពអន្តរសភា និងមូលនិធិខុនរ៉ាដ អាដេណោអ័រ។ កូនសៀវភៅសម្រាប់សភាស្តីពីមេរោគអេដស៍/ជម្ងឺអេដស៍ ត្រូវបានបោះពុម្ពផ្សាយក្រោមកិច្ចសហការជាមួយអ្នកពាក់ព័ន្ធនានារួមមាន UNAIDS, អង្គការសុខភាពគ្រួសារអន្តរជាតិ និងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងជម្ងឺអេដស៍។ សមាជិកសភា បានធ្វើទស្សនកិច្ចនៅសភាអ៊ីតាលី និងឡាវ និងសហភាពអន្តរសភានៅទីក្រុងហ្សឺណែវ និងបានចូលរួមក្នុងបេសកកម្មមួយដើម្បីសិក្សាអំពីដំណើរការប្រជាធិបតេយ្យនៅប្រទេសអ៊ីតាលី។

នៅក្នុងលេខាធិការដ្ឋាន បុគ្គលិកចំនួន ៦៨ រូប (បុរស ៥៥, ស្ត្រី ១៣) បានទទួលការបណ្តុះបណ្តាលលើជំនាញនានា ដូចជាការគ្រប់គ្រងនិងការប្រាស្រ័យឆ្លើយឆ្លងជាយុទ្ធសាស្ត្រ តាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ហើយបុគ្គលិកចំនួន ២៨ នាក់ (បុស ១៩, ស្ត្រី ៩) បានសិក្សាជរលេខខ្មែរ។ អ្នកស្ម័គ្រចិត្ត អ.ស.ប ម្នាក់ បានបង្រៀនភាសាអង់គ្លេសដល់សមាជិកសភា និង បុគ្គលិកដែលនឹងត្រូវចាត់ចែងកិច្ចប្រជុំសហភាពអន្តរសភាអាស៊ាននៅឆ្នាំ ២០១១។ លេខាធិការដ្ឋានសម្របសម្រួលបច្ចេកទេស បានកោះប្រជុំគណៈកម្មាធិការដឹកនាំកិច្ចការសភា ដើម្បីឱ្យអនុវត្តតួនាទីត្រួតពិនិត្យលើជំនួយនានា។ ព្រឹត្តិបត្តិព័ត៌មានមួយ សម្លេងសភា បានគូសបញ្ជាក់ពីសកម្មភាពទាក់ទងនឹងការតាក់តែងច្បាប់ ការធ្វើជាតំណាង និងតុល្យភាពអំណាច។

*"ទស្សនកិច្ចនេះលើកទឹកចិត្តពួកគេឱ្យស្វែងយល់កាន់តែច្រើនអំពីអនាគតរបស់ខ្លួន។ សិស្សខ្លះដែលទើបបញ្ចប់ការសិក្សាថ្នាក់ទី ១២ បានគ្រោងដាក់ពាក្យចូលរៀននៅមហាវិទ្យាល័យច្បាប់ ព្រោះពួកគេចង់ក្លាយជាសមាជិកសភា"*
*លោក ឆេង សូផាណារម្យ នាយកសាលាមធ្យមសិក្សាកោះ ខេត្តកំពង់ចាម*

## ប្រព័ន្ធផ្សព្វផ្សាយដែលមានលក្ខណៈឆ្លើយតប និងវេទិកាអព្យាក្រឹត្យផ្តល់ឱកាសសម្រាប់ការពិភាក្សាតាមបែបប្រជាធិបតេយ្យ

យូអិនឌីភី ធ្វើការដើម្បីកែលម្អដំណើរការបោះឆ្នោតរបស់កម្ពុជា និងដើម្បីបង្កើតឱកាសអព្យាក្រឹត្យសម្រាប់ការពិភាក្សា លើកទឹកចិត្តឱ្យពលរដ្ឋស៊ីវិលចូលរួម និងគណនេយ្យភាពជាសាធារណៈ និងគាំទ្រឱ្យមានសារព័ត៌មានប្រកបដោយតុល្យភាព។ យូអិនឌីភី ធ្វើការជាមួយក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន និងគណៈកម្មាធិការជាតិបោះឆ្នោត (គ.ជ.ប) គណបក្សនយោបាយ និង អង្គការសង្គមស៊ីវិល។ នៅឆ្នាំ ២០០៩ សកម្មភាពនានាបានទទួលមូលនិធិគាំទ្រពី យូអិនឌីភី មូលនិធិប្រជាធិបតេយ្យនៃ អ.ស.ប, AusAID, CIDA, SIDA, មូលនិធិ ត្រាស់សម្រាប់អភិបាលកិច្ចប្រជាធិបតេយ្យ ជំនួយពីប្រទេសអៀរឡង់ និងអុកស្វាមអាមេរិក។

យូអិនឌីភី និងទូរទស្សន៍ជាតិកម្ពុជា ទទក បានគាំទ្រការផលិតព័ត៌មានសមធម៌ប្រចាំសប្តាហ៍ ដោយបានផលិតកម្មវិធីសមធម៌ចំនួន ៥២ លើបញ្ហារសើប ដូចជា ការប្រព្រឹត្តល្បែងនិងការប្លន់ខ្សាច់។ អ្នកកសាងគោលនយោបាយ បានពិចារណាបញ្ហាខ្លះៗ ដែលបានចាក់ផ្សាយ ដោយបានដាក់ចេញនូវចំណាត់ការដើម្បីកែតម្រូវ។ បរិយាកាសផ្សព្វផ្សាយព័ត៌មានកាន់តែមានការលំបាក ដោយរដ្ឋាភិបាលបានឈ្នះរឿងក្តីមួយចំនួន ដោយផ្អែកលើមូលដ្ឋាននៃបទបរិហាកេរ្តិ៍ និងការផ្សព្វផ្សាយព័ត៌មានមិនពិត។ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានចេញលិខិតមួយ ដែលធានាដល់ភ្ញៀវនៅក្នុងកម្មវិធីសមធម៌ប្រចាំសប្តាហ៍ថា ពួកគេនឹងមិនរងការចោទប្រកាន់ ដោយសារតែការបញ្ចេញមតិនៅក្នុងកម្មវិធីនេះឡើយ។ ក្រសួងព័ត៌មានក៏បានបង្កើតនូវការិយាល័យសមធម៌ ដែលជាការបង្ហាញអំពីការប្តេជ្ញារបស់ខ្លួននៅក្នុងការជម្រុញកម្មវិធីសមធម៌ផងដែរ។

កិច្ចប្រឹងប្រែង ដើម្បីកែលម្អការចុះឈ្មោះអ្នកបោះឆ្នោត និងបណ្តឹងចំពោះការបោះឆ្នោត និងដំណើរការឧទ្ធរណ៍ បានប្រឈមនឹងការលំបាក។ ទីប្រឹក្សាច្បាប់របស់សហភាពអឺរ៉ុប ដែលដឹកនាំដំណើរការសម្របសម្រួលជាមួយយូអិនឌីភី បានលើកស្នើវិសោធនកម្មលើច្បាប់បោះឆ្នោត ប៉ុន្តែ គ.ជ.ប បានគូសបញ្ជាក់ថា ខ្លួនមានតួនាទីអនុវត្តច្បាប់ ហើយកំណែទម្រង់ធំទូលាយទាមទារឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗដទៃទៀតដែលរួមទាំងក្រសួងមហាផ្ទៃផងដែរ។ មានការយល់ឃើញថា គ.ជ.ប មានឯករាជ្យភាពខាងស្ថាប័នក្នុងកម្រិតកំណត់តែប៉ុណ្ណោះ ដោយសារសមាជិករបស់ខ្លួនបានទទួលការតែងតាំងពីក្រសួងមហាផ្ទៃនិងបានអនុម័តដោយសភាជាតិតាមសំណើរបស់គណៈរដ្ឋមន្ត្រី។ ក្រោយការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅក្នុងឆ្នាំ ២០០៨ ការអង្កេតលើអ្នកបោះឆ្នោតចំនួន ៨.៦៧៨ នាក់ ដោយអង្គការមិនមែនរដ្ឋាភិបាលមួយឈ្មោះ គណៈកម្មាធិការដើម្បីការបោះឆ្នោត ដោយសេរីនិងយុត្តិធម៌ (COMFREL) ដោយមានការឯកភាពពីក្រសួងមហាផ្ទៃបានរកឃើញថា ប្រជាជនចំនួន ២១,៤% មិនបានទៅបោះឆ្នោតឡើយ ដោយសារតែមិនអាចឃើញឈ្មោះខ្លួននៅក្នុងបញ្ជីអ្នកបោះឆ្នោត ឬ មិនអាចរកស្ថានីយ៍បោះឆ្នោតរបស់ខ្លួនឃើញ។ ការបណ្តុះបណ្តាល និងការគាំទ្រខាងបរិក្ខារដល់កម្មវិធីជាតិផ្តល់អត្តសញ្ញាណប័ណ្ណរបស់ក្រសួងមហាផ្ទៃ ត្រូវបានបន្តអនុវត្ត ប៉ុន្តែកិច្ចប្រឹងប្រែងនានាដើម្បីបង្កើតឱ្យមានទំនាក់ទំនងរវាងកម្រងទិន្នន័យអត្តសញ្ញាណប័ណ្ណរបស់ក្រសួងមហាផ្ទៃ និងការចុះឈ្មោះបោះឆ្នោតរបស់ គ.ជ.ប មិនបានឈានទៅមុខឡើយ។ ការពិភាក្សានានាស្តីពីការកែលម្អប្រព័ន្ធចុះឈ្មោះ មិនបានឈានដល់កិច្ចព្រមព្រៀងឡើយ ដោយសារភាគីឈ្នះឆ្នោតបានដកស្រង់របាយការណ៍ពីអ្នកសង្កេតការណ៍អន្តរជាតិ ដែលបានអធិប្បាយការបោះឆ្នោតឆ្នាំ ២០០៨ ថាបានប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌។ បេសកកម្មសង្កេតការណ៍របស់ EU សម្រាប់ការបោះឆ្នោតនៅឆ្នាំ ២០០៨ បានស្វាគមន៍ការកែលម្អនានា ប៉ុន្តែក៏បានសន្និដ្ឋានផងដែរថា ការបោះឆ្នោតនេះមានកម្រិតទាបជាងស្តង់ដារមួយចំនួននៃការបោះឆ្នោតអន្តរជាតិ។ យូអិនឌីភី និងដៃគូរបស់ខ្លួនបានគាំទ្រឱ្យមានការប្រជុំមួយដែលក្នុងនោះ គ.ជ.ប បានផ្តល់បញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលបានធ្វើបច្ចុប្បន្នភាព ហើយអ្នកចូលរួមពីភាគីឈ្នះឆ្នោត និងភាគីជំទាស់ទាំងបួន អាចសំដែងយោបល់របស់ខ្លួនលើបញ្ជីនោះ។

សិក្ខាសាលាស្តង់ដារនៃការបោះឆ្នោត ដែលមានអ្នកចូលរួមចំនួន ១.៤១០ នាក់ (បុរស ៨៩៨, ស្ត្រី ៥១២) បានធ្វើឡើងនៅក្នុងខេត្តចំនួនបួន ដើម្បីឱ្យអ្នកបោះឆ្នោត បានដឹងអំពីវេទិកានយោបាយ និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល។ របាយការណ៍មួយដែលថ្លែងលំអិតអំពីលក្ខខណ្ឌអប្បបរមា និងការប្តេជ្ញាដោយមន្ត្រីនានាត្រូវបានចេញផ្សាយនៅពេលក្រោយមក។ វេទិកាសាធារណៈនៅមូល ដ្ឋានចំនួន ២០ ដែលមានការចូលរួមពីប្រជាជនចំនួន ១.៣១៦ នាក់ (បុរស ៦៥៩, ស្ត្រី ៥៥៧) បង្កលក្ខណៈ ឱ្យអ្នកបោះឆ្នោតបានជួបជាមួយសមាជិកក្រុមប្រឹក្សាឃុំ ហើយអ្នកសង្កេតការណ៍នៅមូលដ្ឋានចំនួន ៣៧ នាក់ (បុរស ២៤, ស្ត្រី ១៣) ត្រូវបានជ្រើសរើសឱ្យតាមដានមើលការប្តេជ្ញារបស់សមាជិកក្រុមប្រឹក្សាទាំងនោះ។

អង្គការ COMFREL ដែលបានរៀបចំអត្ថបទអំពីប្រវត្តិ សង្ខេបរបស់សមាជិកសភា និងតាមឃ្លាំមើលបេសកកម្មរបស់សមាជិកសភាទៅមូលដ្ឋានបានរកឃើញថា សមាជិកសភាចំនួន ៩៩ រូប បានធ្វើទស្សនកិច្ចចំនួន ១.០៤២ លើក នៅក្នុងឆ្នាំ ២០០៩។




*និស្សិតនៅសកលវិទ្យាល័យ បៀលប្រាយ ខេត្តបន្ទាយមានជ័យ ពិភាក្សាបញ្ហានានាដែលលើកឡើងនៅក្នុងកម្មវិធីទូរទស្សន៍សមធម៌ ដែលបានចែកចាយតាមរយៈឌីវីឌី ដើម្បីផ្សព្វផ្សាយឱ្យដល់គោលដៅទូលំទូលាយ។ (យូអិនឌីភី/ក្រេក ឡាវិនឌ័រ)*



*លោកស្រី ឆ្លួយ គឹមស្រេ ប្រធាននាយកដ្ឋានផែនការ និងស្ថិតិនៃក្រសួងកិច្ចការនារី ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកនៅវិទ្យាស្ថានជាតិស្ថិតិ អំពីយេនឌ័រ និងស្ថិតិ។ (យូអិនឌីភី/ប៉ាទ្រីស្យ៉ា អាឡិកសាន់ឌ័រ)*

## គោលនយោបាយ និងកំណែទម្រង់នានា លើកកំពស់សមធម៌យេនឌ័រ និងពង្រឹងសិទ្ធិអំណាចស្ត្រី

ជាទូទៅ ស្ត្រីកម្ពុជាមានឋានានុក្រមទាបជាងបុរសនៅក្នុងគ្រួសារ និងសេដ្ឋកិច្ច និងក្នុងគ្រប់ស្រទាប់នៃសង្គម។ ពួកគេនូវតែប្រឈមនឹងកំហិតក្នុងលទ្ធភាពទទួលបានការអប់រំ ការថែទាំសុខភាព ឱកាសខាងការងារ និងមុខរបរ។ ពួកគេក៏រងគ្រោះ ដោយសារអំពើហឹង្សាខាងយេនឌ័រនិងការជួញដូរមនុស្សក្នុងកម្រិតមួយដ៏វិសមាមាត្រផងដែរ។ យូអិនឌីភី ធ្វើការជាមួយក្រសួងកិច្ចការនារី ដើម្បីពង្រឹងសមត្ថភាពជាតិ និងការឆ្លើយតបនៅក្នុងការលើកកំពស់សមធម៌យេនឌ័រ និងការពង្រឹងសិទ្ធិអំណាចរបស់ស្ត្រី។ យូអិនឌីភី ផ្តល់ការតស៊ូមតិការស្រាវជ្រាវ ការបណ្តុះបណ្តាល ការហ្វឹកហ្វឺន ផ្តល់ដំបូន្មាន និង ការណែនាំខាងគោលនយោបាយ និងបច្ចេកទេសដល់ក្រសួងកិច្ចការនារីនិងក្រសួងពាក់ព័ន្ធ។ ដៃគូនានាធ្វើការដើម្បីដាក់បញ្ចូលកង្វល់ខាងយេនឌ័រទៅក្នុងគោលនយោបាយ កម្មវិធីកំណែទម្រង់ ការកំណត់ថវិកា ការអនុវត្ត និងក្របខ័ណ្ឌតាមដាន។ ដៃគូទាំងនោះក៏គាំទ្រផងដែរដល់ការបង្កើតឱកាសរកប្រាក់ចំណូល និងជំនាញវិជ្ជាជីវៈ និង សហគ្រិនសម្រាប់ស្ត្រីនៅជនបទ និងស្ត្រីក្រីក្រ។

នៅឆ្នាំ ២០០៩ ការប្តេជ្ញារឹងមាំមួយស្តីពីសមធម៌ យេនឌ័រ ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម(២០០៩-២០១៣)។ ផែនការយុទ្ធសាស្ត្រនេះ រួមបញ្ចូលយុទ្ធសាស្ត្រសមធម៌យេនឌ័រនៅក្នុងវិស័យនានា ដូចជា ទេសចរណ៍ ការងារ និងកសិកម្ម រួមនឹងចំណុចដៅស្នូលនិងសូចនាករនានាដែលទាក់ទងនឹងសមភាពយេនឌ័រ ក៏ដូចជា ទិន្នន័យដែលបែងចែកតាមភេទសម្រាប់តាមដាន និងវាយតម្លៃផងដែរ។ ក្រសួងពាក់ព័ន្ធស្ទើរទាំងអស់មានក្រុមការងារបញ្ជ្រាបយេនឌ័រ និង បានបង្កើតផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ ដែលផ្តល់ជាយន្តការសម្រាប់អនុវត្តនិងតាមដានការប្តេជ្ញាខាងគោលនយោបាយរបស់រដ្ឋាភិបាលនៅតាមកម្រិតវិស័យ។ ការគិតគូរទាំងឡាយអំពីសមភាពយេនឌ័រត្រូវបានដាក់បញ្ចូលក្នុងសកម្មភាព និងសូចនាករតាមដាននៃសេចក្តីព្រាងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩)។ សារាចររបស់ក្រសួងស្តីពីគណៈកម្មការពិគ្រោះយោបល់អំពីស្ត្រី និងកុមារនៅថ្នាក់ខេត្ត និងស្រុកត្រូវបានរៀបចំរួចរាល់ ដូចជា សេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាព សម្រាប់ស្ត្រីនៅក្នុងតំណែងធ្វើការសម្រេចនៅថ្នាក់ក្រោមជាតិ។ ដំណើរការកែទម្រង់រដ្ឋបាលសាធារណៈ បានលើកឡើងនូវបញ្ហាយេនឌ័រ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាកែទម្រង់រដ្ឋបាល។ ឯកសារណែនាំមួយក្រោមចំណងជើងថាធ្វើឱ្យអភិបាលកិច្ចឆ្លើយតបនឹងទិដ្ឋភាពយេនឌ័រ ត្រូវបានរៀបរៀងឡើងសម្រាប់ការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីស៊ីវិល។

សមាមាត្រនៃតំណែងនៅក្នុងរដ្ឋាភិបាល ដែលកាន់កាប់ដោយស្ត្រី បានកើនឡើងពី ៣២% នៅក្នុងឆ្នាំ ២០០៨ ដល់ ៣៤% នៅឆ្នាំ ២០០៩ ធៀបនឹងចំណុចដៅ ៣៥% រហូតដល់ឆ្នាំ ២០១០ ដែលមានចែងនៅក្នុងផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ និង គោលការណ៍ណែនាំឆ្នាំ ២០០៨ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។ សាលាភូមិន្ទរដ្ឋបាលបានបញ្ចូលសមភាពយេនឌ័រទៅក្នុងកម្មវិធីរបស់ខ្លួន ហើយវគ្គបណ្តុះបណ្តាលអំពីយេនឌ័រនៅក្នុងសាលានេះត្រូវបានផ្តល់សម្រាប់មន្ត្រីចំនួន ៣០០ នាក់ និង និស្សិតចំនួន ៥០ នាក់។ យូអិនឌីភី បានគាំទ្រដល់ក្រសួងកិច្ចការនារីក្នុងការកសាងផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំលើកទីបី នារីរតនៈ III។ ផែនការនេះ បានគាំទ្រដល់លេខាធិការដ្ឋានក្រុមការងារបច្ចេកទេសយេនឌ័រ (TWG-G) ដែលក្នុងនោះមានតំណាងរដ្ឋាភិបាល ដៃគូរអភិវឌ្ឍន៍ និងសង្គមស៊ីវិល។ ក្រុមការងារនេះ បានធ្វើផែនការសកម្មភាពសូចនាករតាមដានរួមគ្នា និងរបាយការណ៍ទៀងទាត់សម្រាប់ដាក់ជូនទៅ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់គណៈកម្មាធិការពិគ្រោះយោបល់រដ្ឋាភិបាលម្ចាស់ជំនួយ។ ក្រសួងកិច្ចការនារី និងក្រុមការងារនេះ បានទទួលការគាំទ្រពីដៃគូនានាក្នុងការអនុវត្តអភិក្រមផ្អែកលើកម្មវិធី ដើម្បីបញ្ជ្រាបយេនឌ័រ ដែលមានគោលដៅបង្រ្កីជំនួយអភិវឌ្ឍន៍នៅជុំវិញអាទិភាព និងផែនការរបស់ជាតិ ជាងតាមរយៈគម្រោងដែលដឹកមុខដោយម្ចាស់ជំនួយ។ មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីនៅខេត្តកំពង់ស្ពឺ ដែលជាកិច្ចផ្តួចផ្តើមមួយគាំទ្រដោយយូអិនឌីភី ក្រសួងកិច្ចការនារី និងមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ បានរៀបរៀងរបាយការណ៍នានា ស្តីពីការសិក្សាឱកាសខាងទីផ្សារលើការត្បាញក្រមា ការផលិតកម្រាលជូតជើងពីកំទេចក្រណាត់រោងចក្រកាត់ដេរ និងការផលិតស្ករត្នោត។